**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
******

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
******

នៅព្រឹកថ្ងៃទី **២២ ខែសីហា** ឆ្នាំ២០១៨ **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួបលោក Haoliang Xu ឧបការីអគ្គលេខាធិការអង្គការសហប្រជាជាតិ និងជានាយកកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក នៅទីស្តីការក្រសួង។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានស្វាគមន៍លោក Haoliang Xu ដែលបានអញ្ជើញមកកម្ពុជាចូលរួមធ្វើជាអធិបតីភាពក្នុងសន្និសីទស្តីពី **"មូលដ្ឋានីយកម្ម នៃការអភិវឌ្ឍប្រកបដោយចីរភាព និងការសម្រេចបាននូវការលុបបំបាត់ភាពក្រីក្រ"** ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២០-២១ ខែសីហា ឆ្នាំ២០១៨ នៅខេត្តសៀមរាប។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ទីភ្នាក់ងារអ.ស.ប ប្រចាំកម្ពុជា (United Nations Country Team- UNCT) ដែលតែងតែសហការល្អប្រសើរ ជាមួយរាជរដ្ឋាភិបាលលើការអភិវឌ្ឍនៅកម្ពុជាក្នុងកិច្ចខិតខំសម្រេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នាពេលកន្លងមក ក៏ដូចជាបន្តជម្រុញដល់ការឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ នៅក្នុងវិស័យពាក់ព័ន្ធទាំងឡាយ ដូចជា វិស័យអប់រំ សុខាភិបាល កសិកម្ម សមភាពយេនឌ័រ ការបោសសំអាតមីន និងបេសកកម្មរក្សាសន្តិភាព។

លោកឧបការី បានកោតសរសើរ និងបានកត់សំគាល់នូវល្បឿនវឌ្ឍនភាព និងការរីកលូតលាស់នៅកម្ពុជានាពេលបច្ចុប្បន្ន ទាំងលើវិស័យហេដ្ឋារចនាសម្ព័ន្ធ កំណើនសេដ្ឋកិច្ច ចំណេះជំនាញ និងការផ្តល់ការងារធ្វើដល់ពលរដ្ឋកម្ពុជា។ល។ ដែលទាំងនេះ រួមចំណែកសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ UNDP ត្រៀមផ្តល់កិច្ចសហការគាំទ្រចំពោះប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសនានានៅអាស៊ី ពិសេសលើវិស័យអភិបាលកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាជន។

លោកឧបការីក៏បានសម្តែងនូវការប្តេជ្ញាចិត្តរបស់អង្គការសហប្រជាជាតិ ក្នុងការគាំទ្ររយៈកាលអន្តរកាលប្រាក់ចំណូលមធ្យមរបស់កម្ពុជា ប្រកបដោយបរិយាប័ន្ន និងសមធម៌សម្រាប់មនុស្សគ្រប់រូប ស្របតាមការប្តេជ្ញាចិត្តរបៀបវារៈឆ្នាំ ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ លោកបានគូសបញ្ជាក់ថា កំណើនប្រកបដោយបរិយាប័ន្នអាចសម្រេចបាន ដោយការធ្វើសមាហរណកម្មគំនិតពិចារណាបរិស្ថាន និងសង្គម តាមរយៈការលើកកំពស់ស្ថាប័នអភិបាលកិច្ច ភាពជាដៃគូ និងនវានុវត្ត អោយបានរឹងមាំ។ លោកក៏បានថ្លែងកោតសរសើរដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរួមបញ្ចូលគោលដៅទី១៨ ស្តីពីសកម្មភាពមីននៅកម្ពុជា ទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់លោក ឧបការី ដែលបានលើកទឹកចិត្តដល់កម្ពុជា និងបានគូសបញ្ជាក់ថា ការសម្រេចបានការអភិវឌ្ឍទាំងនេះ គឺដោយសារប្រទេសកម្ពុជាមានសុខសន្តិភាព ក្នុងរយៈ២

ទសវត្សមកនេះ និងបានបញ្ជាក់ថា កម្ពុជាមានបំណងចង់ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នាឆ្នាំ ២០៣០ ដែលនេះគឺស្របនឹងគោលដៅប្រកបដោយចីរភាពរបស់អ.ស.ប ឆ្នាំ២០៣០។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បន្ថែមថា រាជរដ្ឋាភិបាលអណត្តិថ្មី នឹងបន្តផ្តល់សារៈសំខាន់នៃគោលដៅអភិវឌ្ឍន៍របស់អ.ស.ប តាមរយៈការអនុម័តគោលដៅនេះជាផែនការថ្នាក់ជាតិ ហើយកម្ពុជាបានបន្ថែមវិស័យសកម្មភាពដោះមីនជាគោលដៅទី១៨ នៃ ការអភិវឌ្ឍរបស់កម្ពុជា។

កិច្ចពិភាក្សា បានបញ្ចប់ ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃសុក្រ ១៤ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៨